**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2011, 11:56
CMS/CFO: Sann Rada

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

កាលបរិច្ឆេទឯកសារ៖ ១៧ មីនា ឆ្នាំ ២០១១

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ បារាំង

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សេចក្តីសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើញត្តិរបស់លោក អៀង សារី**
**សុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ មុនពេលធ្វើសក្ខីកម្ម**

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** | **អង្គជំនុំជម្រះសាលាដំបូង៖** |
| មេធាវី ពេជ អង្គ | ចៅក្រម និល ណុន ប្រធាន |
| មេធាវី Elisabeth SIMONNEAU-FORT | ចៅក្រម Silvia CARTWRIGHT |
| **សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** | ចៅក្រម យ៉ា សុខន |
| មេធាវី ជេត វណ្ណលី មេធាវី គឹម ម៉េងឃី | ចៅក្រម Jean-Marc LAVERGNE |
| មេធាវី ហុង គឹមសួន មេធាវី ឡោ ជុនធី | ចៅក្រម ធូ មណី |
| មេធាវី ម៉ុច សុវណ្ណារី មេធាវី ស៊ិន សុវ៉ន | |
| មេធាវី សំ សុគង់ មេធាវី វ៉ែន ពៅ | |

មេធាវី ទី ស្រីនណា
មេធាវី Emmanuel ALTIT
មេធាវី Pascal AUBOIN
មេធាវី Olivier BAHOUGNE
មេធាវី Patrick BAUDOIN
មេធាវី Evelyne BOILEAU-BRANDOMIR
មេធាវី Philippe CANONNE
មេធាវី Annie DELAHAIE
មេធាវី Laure DESFORGES
មេធាវី Ferdinand DJAMMEN NZEPA
មេធាវី Nicole DUMAS
មេធាវី Isabelle DURAND
មេធាវី Françoise GAUTRY
មេធាវី Marie GUIRAUD
មេធាវី Emmanuel JACOMY
មេធាវី Martine JACQUIN
មេធាវី Daniel LOSQ
មេធាវី Christine MARTINEAU
មេធាវី Madhev MOHAN
មេធាវី Barnabé NEKUIE
មេធាវី Lyma Thuy NGUYEN
មេធាវី Elisabeth RABESANDRATANA
មេធាវី Julien RIVET
មេធាវី Fabienne TRUSSES NAPROUS
មេធាវី Nushin SARKARATI

<u>ចម្លងជូន៖</u>

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉ែត ចរិយា
លោក William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន
អៀង សារី
អៀង ធីរិទ្ធ
នួន ជា

**សហមេធាវីការពារក្តី៖**

មេធាវី សុន អរុណ
មេធាវី Michiel PESTMAN
មេធាវី Victor KOPPE
មេធាវី អាង ឧត្តម
មេធាវី Michael G. KARNAVAS
មេធាវី ផាត់ ពៅសៀង
មេធាវី Diana Ellis
មេធាវី ស សូវាន
មេធាវី Jacques VERGES
មេធាវី Philippe GRECIANO

## សេចក្ដីផ្ដើម

១. សហមេធាវីការពារក្ដីលោក អៀង សារី បានដាក់ញត្តិមួយកាលពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្នើសុំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលកោះហៅឲ្យមកផ្ដល់សក្ខីកម្មនាពេលសវនាការ ក្នុងក្របខណ្ឌនៃរឿងក្ដី ធ្វើសម្បថជាមុនសិន[1]។

២. សហមេធាវីការពារលោក អៀង សារី បានទាមទារថា នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដើមបណ្ដឹងរដ្ឋប្បវេណីនោះត្រូវតែធ្វើសម្បថ ពោលគឺដូចគ្នាទៅនឹងសាក្សីទាំងអស់ដែរ ក្នុងករណីដែលសក្ខីកម្មរបស់ពួកគេអាចជះឥទ្ធិពលទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ។

៣. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា សំណើសុំនេះដើរបញ្ច្រាសពីគោលការណ៍ទូទៅនៃច្បាប់ ព្រមទាំងវិធានជាក់លាក់នានាដែលចែងអំពីនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក."។ ហេតុដូច្នេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាបដិសេធញត្តិសុំនេះ។

## ការពិភាក្សា

### ជាចម្បង នៅលើភាពពុំមានយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង÷

៤. វិធាន ២៣(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងថា *"ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចត្រូវបានស្ដាប់យកចម្លើយក្នុងឋានៈជាសាក្សី នៅក្នុងសំណុំរឿងតែមួយបានឡើយ ហើយលើកលែងតែវិធាន៦២ ដែលចែងពាក់ព័ន្ធនឹងដីកាចាត់ឲ្យស៊ើបសួរជំនួស ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានស្ដាប់យកចម្លើយ តែក្នុងល័ក្ខខ័ណ្ឌដែលអនុវត្តដូចគ្នាទៅលើជនត្រូវចោទ ឬជនជាប់ចោទ"*។ ដោយឡែក យោងទៅលើវិធានផ្ទៃក្នុង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ល័ក្ខខ័ណ្ឌនានាដែលពាក់ព័ន្ធនឹងការស្ដាប់ចម្លើយជនត្រូវចោទ ឬជនជាប់ចោទ ពុំ

[1] សំណើរបស់ អៀង សារី ស្នើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសម្បថ ប្រសិនបើត្រូវបានអនុញ្ញាតឲ្យផ្ដល់សក្ខីកម្ម អំពីអ្វីដែលពួកគាត់បានដឹងពីរឿងក្ដីព្រហ្មទណ្ឌ ឯកសារ E57។

តម្រូវឲ្យមានការធ្វើសម្បថណាមួយឡើយ។

៥. សំណើសុំរបស់សហមេធាវីការពារក្តីលោក អៀង សារី ដែលមានគោលដៅដាក់កំហិតឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលយកទម្រង់ការណាមួយ ត្រូវបានវិភាគឃើញថាជាសំណើសុំធ្វើការកែប្រែជាសារវន្តទៅលើបទបញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

៦. ដោយឡែក ការកែប្រែបែបនេះជាយុត្តាធិការផ្តាច់មុខរបស់កិច្ចប្រជុំពេញអង្គ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងប្រកាសថា ខ្លួនពុំមានយុត្តាធិការក្នុងការជំនុំជម្រះលើសំណើសុំនេះឡើយ។

## ជាបន្ទាប់បន្សំ នៅលើខ្លឹមសារនៃសំណើរបស់សហមេធាវីការពារលោក អៀង សារី:

*ទៅលើចរិតលក្ខណៈមិនទៀងទាត់នៃការរឹតត្បិតចំពោះសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង00១ ពាក់ព័ន្ធទៅនឹងការហាមឃាត់ដាក់លាក់ចំពោះពួកគេ*

៧. នៅក្នុងសំណុំរឿង00១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការជំនុំជម្រះដោយចេញសេចក្តីសម្រេចមួយ ចុះថ្ងៃទី 0៩ ខែ តុលា ឆ្នាំ ២00៩[2] ពាក់ព័ន្ធទៅនឹងតួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលនៃរឿងក្តី ដែលសហមេធាវីការពារក្តីលោក អៀង សារី បានប្រើប្រាស់សេចក្តីសម្រេចនោះធ្វើជាមូលដ្ឋានសម្រាប់ទឡ្ហីកម្មរបស់ខ្លួន។

៨. ពិតមែនតែសេចក្តីសម្រេចនេះបានកម្រិតដោយអយុត្តិធម៌នូវអន្តរាគមន៍របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងការសួរចម្លើយដែលប៉ះពាល់ទៅដល់បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ តែសេចក្តីសម្រេចនេះបានផ្តល់តួនាទីដ៏ទូលំទូលាយដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ដែលជាការអនុវត្តនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក.។ សេចក្តីសម្រេចក៏បានធ្វើការបញ្ជាក់ផងដែរថា គេបានប្រគល់ទាំង

---

[2] សំណុំរឿង 00១/១៨ កក្កដា ២00៧-អវតក/អជសជ, សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ឯកសារ E72/3។

ស្រុងនូវឋានៈជាភាគីនៃរឿងក្ដីដល់ដើមបណ្ដឹងរដ្ឋប្បវេណី ពោលគឺពួកគេអាចចូលរួមជាមួយស្ថាប័នដែលមានភារៈចោទប្រកាន់ក្នុងការបង្ហាញនូវការពិត[3]។ គោលដៅរួមគ្នានេះជាការអះអាងបញ្ជាក់ពីទំហំនៃភាពបត់បែននៅក្នុងអំឡុងពេលនៃការជំនុំជម្រះ ទាក់ទងនឹងការរៀបចំភ័ស្តុតាង ការរៀបចំសក្ខីកម្មរបស់សាក្សីឬអ្នកជំនាញ និងការចាត់ចែងអន្តរាគមន៍ក្នុងអំឡុងពេលនៃការសួរចម្លើយ។

៩. ម្យ៉ាងទៀត សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ស្ថិតក្នុងករណីពិសេសនៃសំណុំរឿង០០១ ដែលកត់សម្គាល់ឃើញតាមរយៈចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃដើមបណ្ដឹងរដ្ឋប្បវេណី។ ចំនួននៃដើមបណ្ដឹងរដ្ឋប្បវេណីដែលបានកើនឡើងក្នុងសំណុំរឿង ០០២ បានជំរុញឲ្យមានជាការបង្កើតនូវសហមេធាវីនាំមុខ ដែលត្រូវ "ធានាឲ្យមានប្រសិទ្ធិភាពអំពីការរៀបចំការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[...] ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឲ្យការជំនុំជម្រះក្ដីប្រព្រឹត្តទៅបានឆាប់រហ័ស [...] "[4]។

១០. ចំណាត់ការថ្មីនេះមានគោលដៅជំទាស់ទៅនឹងការរឹតត្បិត ដែលបានដាក់ចេញតាមរយៈសេចក្ដីសម្រេចចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ពាក់ព័ន្ធ នឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទៅក្នុងការសួរចម្លើយស្ដីអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ។ ជាក់ស្ដែងការដាក់កម្រិតនេះមានហេតុផលរបស់វា ដោយសារប្រភេទនៃរឿងក្ដី និងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃជនរងគ្រោះ[5] ពោលគឺជាធាតុផ្សំដែលមានលក្ខណៈមិនទៀងទាត់ និងមានភាពបត់បែនទៅតាមបរិបទ។

១១. ចាប់តាំងពីមានការបង្កើតឲ្យមានសហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមកទឡ្ហីករណ៍នេះនឹងពុំមានទម្ងន់ដូចគ្នានោះទេ ក្នុងការបញ្ជាក់អះអាងពីភាពខុសគ្នា ទាក់ទងនឹងតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីឡើយ។

---

[3] ដូចខាងលើ កថាខណ្ឌ៤១។

[4] វិធាន ១២ ស្ទួនពីរ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[5] សេចក្ដីសម្រេច ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ១២។

១២. បរិបទនីតិវិធីថ្មីនេះ ដែលពាក់ព័ន្ធនឹងការរៀបចំដើមបណ្ដឹងរដ្ឋប្បវេណី បានជួយពង្រឹងទស្សនៈដោយឡែករបស់ចៅក្រម Lavergne នៅក្នុងពេលចេញសេចក្ដី សម្រេចថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២00៩។ លោកចៅក្រម Lavergne បានរំលឹកថា នីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដូចជាវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. បានទទួលស្គាល់ថាដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងភាគីដទៃទៀតនៃរឿងក្ដីដែរ[6] នៅគ្រប់ដំណាក់កាលនៃនីតិវិធី ដោយគ្មានការបែងចែកណាមួយផ្អែកលើកម្មវត្ថុ (អង្គហេតុ ឬបុគ្គលិកលក្ខណៈ) នៃការផ្ដល់សក្ខីកម្ម ឬកោសល្យវិច័យឡើយ[7] លើកលែងតែមានបទបញ្ញត្តិជាក់លាក់ចែងផ្ទុយពីនេះ។ ម្យ៉ាងទៀត ការបែងចែកបែបនេះប៉ះពាល់ដល់គោលការណ៍នៃការសួរដេញដោលចំពោះមុខ ដែលគោលការណ៍នេះអនុញ្ញាតឲ្យមានការពិភាក្សាជាចំហនៅចំពោះមុខភាគីនីមួយៗ ពាក់ព័ន្ធទៅនឹងភស្តុតាងទាំងឡាយដែលបានបង្ហាញឡើង[8]។

១៣. ជាផលវិបាក និងជាការឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងដោយមេធាវីការពារលោក អៀង សារី ពាក់ព័ន្ធនឹងចំណុចនេះ ប្រសិនណាជាសំណុំរឿង 00១ អាចបង្កើតឲ្យមានការពិភាក្សាអំពីតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងនៃកិច្ចពិភាក្សា ការកម្រិតព្រំដែនធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង មានជាប់ទាក់ទិនទៅនឹងកាលៈទេសៈពិសេសនៃការរៀបចំ និងការប្រព្រឹត្តិទៅនៃកិច្ចពិភាក្សានៅក្នុងសំណុំរឿង00១។ លើសពីនេះ ការកម្រិតព្រំដែននេះពុំបានចោទជាបញ្ហាដល់ការទទួលដើមបណ្ដឹងរដ្ឋប្បវេ-ណី ថាមានលក្ខណៈសម្បត្តិពេញលេញជាភាគីនៃរឿងក្ដីឡើយ។

*ទៅលើក្របខ័ណ្ឌនៃបទដ្ឋានទូទៅដែលពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖*

១៤. វិធាន២៣(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានកំណត់អំពីតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយបានលើកឡើងថា *"គោលបំណងនៃបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្ប*

[6] សេចក្ដីសម្រេច ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២00៩ មតិជំទាស់របស់ចៅក្រម Lavergne កថាខណ្ឌ១៣។

[7] ដូចខាងលើ កថាខណ្ឌ១៨។

[8] ដូចខាងលើ កថាខណ្ឌ១៧។

*វេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី [...] ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់"*។

១៥. លើសពីនេះ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក បានផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី នូវតួនាទីមួយក្នុងកិច្ចពិភាក្សាដេញដោល ដូចគ្នាទៅនឹងភាគីដទៃទៀតដែរ (មេធាវីការពារ និងសហព្រះរាជអាជ្ញា)។ ជាតឹកតាង ជាពិសេសវិធាន ៩១ វាក្យខណ្ឌ ២ និង ៣ បានចែងថា *"ចៅក្រមអាចសួរសំណួរបានគ្រប់បែបយ៉ាង ហើយសហព្រះរាជអាជ្ញា **ភាគីទាំងអស់** និងមេធាវីត្រូវបានអនុញ្ញាតឲ្យសួរសំណួរ ដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង"* ហើយ *"សហព្រះរាជអាជ្ញា **ភាគីទាំងអស់** និង មេធាវីអាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សី ដែលកំពុងដំណើរការ ប្រសិនបើខ្លួនយល់ថា ចម្លើយរបស់សាក្សីនោះមិនមានប្រយោជន៍ដល់ការសម្តែងឲ្យឃើញការពិត"* ។

១៦. បទបញ្ញត្តិទាំងនេះស្របទៅនឹងច្បាប់នីតិវិធីកម្ពុជា ដែលចែងអំពីការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងអន្តរាគមន៍របស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងឋានៈជាភាគីពេញសិទ្ធិ។ ឧទាហរណ៍ មាត្រា៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា *"ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរសួរ"* - ភាគីសំដៅជាទូទៅដល់មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី។ ទូទៅជាងនេះទៅទៀតនេះ ពាក់ព័ន្ធនឹងការចូលរួមក្នុងកិច្ចពិភាក្សាដេញដោល និងការគ្រប់គ្រងភស្តុតាង មាត្រា៣៣៤ នៃក្រមដដែលនេះចែងថា *"រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសម្តែងឲ្យឃើញការពិត"*។

១៧. ចំពោះតុលាការអន្តរជាតិ ជាឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងសាលដីកា ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨[9] បានទទួលស្គាល់

---

[9] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារ

សិទ្ធិរបស់ជនរងគ្រោះអ្នកចូលរួម ភ្លាមៗក្រោយពេលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងរឿងក្តីត្រូវបានបញ្ជាក់ ក្នុងការមិនដាក់កម្រិតការអន្តរាគមន៍មកត្រឹមសំណើសុំសំណងនោះទេ ដោយសារពួកគេត្រូវបានអនុញ្ញាតឲ្យបង្ហាញភ័ស្តុតាងពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ឬជំទាស់ទៅនឹងភាពអាចទទួលយកបាន ឬភាពពាក់ព័ន្ធនៃឯកសារសំណុំរឿង ពោលគឺនិយាយដោយខ្លី ទទួលបានលទ្ធភាពច្រើនក្នុងរឿងក្តី និងសេរីភាពនិយាយស្តីជាទូទៅ ប្រហាក់ប្រហែលគ្នានឹងឋានៈដែលព្រះរាជអាជ្ញាទទួលបានដែរ។ ការចូលរួមយ៉ាងសកម្មបែបនេះរបស់ជនរងគ្រោះមានលក្ខណៈប្រដំប្រសងគ្នាទៅនឹងឋានៈជាភាគីនៃរឿងក្តី ដែល អ.វ.ត.ក ទទួលស្គាល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ អ្វីដែលបង្កើតជាអប្បបរមានៅក្នុងក្របខ័ណ្ឌនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលយកលំនាំតាមប្រព័ន្ធច្បាប់ « Common Law » កាន់តែមិនអាចបង្កជាការលំបាក នៅក្នុងក្របខ័ណ្ឌនៃ អ.វ.ត.ក បានឡើយ។

១៨. យោងតាមធាតុជាបទដ្ឋានទាំងអស់នេះ ការបកស្រាយរបស់សហមេធាវីការពារក្តីលោក អៀង សារី ដោយដាក់កម្រិតទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មកត្រឹមសំណើសុំសំណង (កថាខណ្ឌ៦ និងកថាខណ្ឌ៩ នៃសំណើ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១) ផ្អែកលើការមើលឃើញតែមួយជ្រុង និងភាន់ច្រឡំ ពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបារាំង ដែលជាប្រភពនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

១៩. សហមេធាវីការពារក្តីលោក អៀង សារី លើកឡើងយ៉ាងច្បាស់ថា *"នៅក្នុងតុលាការជាតិកម្ពុជា សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីអាចយកមកប្រើប្រាស់ សម្រាប់សម្រេចលើការទាមទារសំណងរបស់ខ្លួនតែប៉ុណ្ណោះ"*[10]។ សំណើខុសឆ្គងនេះកើតចេញពីការបកស្រាយសម្រង់នៃកំណត់សម្គាល់ជើងទំព័រលេខ២៤ នៃញត្តិរបស់ខ្លួន ដែលបានលើកឡើងថា *"ចៅក្រម [កម្ពុជា] ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី [...] ពាក់ព័ន្ធនឹងព្យសនកម្ម"*។ ខ្លឹមសារដែលបានផ្តល់ទៅឲ្យសម្រង់នេះគឺជាការរំលោភបំពានយ៉ាងច្បាស់

---

ក្តី ប្រឆាំងនឹងសេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ដោយអង្គជំនុំជម្រះសាលាដំបូង I អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ១០៥។

[10] សំណើរបស់សហមេធាវីលោក អៀង សារី ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ E57 កថាខណ្ឌ៦។

ក្រឡែត ពោលគឺលទ្ធភាពដែលផ្តល់ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបញ្ចេញមតិ នៅចំពោះមុខចៅក្រមកម្ពុជា ពាក់ព័ន្ធទៅនឹងព្យសនកម្មដែលខ្លួនបានទទួលរង មិនមែនមានន័យថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានបុព្វសិទ្ធិទូលំទូលាយជាងនេះនោះទេ។

២០. ដូចគ្នាផងដែរ ដើម្បីគាំទ្រដល់ទស្សនៈដាក់កម្រិតជាអប្បបរមាដល់ការអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ញត្តិដែលត្រូវបានជំទាស់បានលើកឡើងថា អត្ថបទច្បាប់បង្កើត អ.វ.ត.ក ពោលគឺកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានចែងអ្វីទាំងអស់ស្តីពីការចូលរួមរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធី[11]។ ក៏ប៉ុន្តែ មាត្រា១២ និងមាត្រា៣៣ នៃអត្ថបទទាំងពីរនេះ ចែងយ៉ាងច្បាស់ថា ត្រូវអនុវត្តច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាធាតុសំខាន់មួយ។

២១. អាស្រ័យហេតុនេះ ទាំងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងអត្ថបទច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬអត្ថបទស្តីពីការអនុវត្ត មិនបានចែងថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវរឹតត្បិតមកត្រឹមការចូលរួមនៅក្នុងការជំនុំជម្រះក្តី ដែលកម្រិតត្រឹមសំណើសុំសំណងរបស់ពួកគេឡើយ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការទាំងមូល ក្នុងឋានៈជាភាគីពេញសិទ្ធិ ដោយអាចបង្ហាញអ្នកជំនាញ និងសាក្សី ធ្វើអន្តរាគមន៍ចំពោះអង្គហេតុទាំងមូលនៃរឿងក្តី យោងតាមក្របខ័ណ្ឌច្បាប់ដែលបានលើកឡើងខាងលើ និងការអនុវត្តរបស់តុលាការដែលកើតចេញពីក្របខ័ណ្ឌច្បាប់នោះ។

*ទៅលើវិសមិតភាពរវាងការធ្វើសម្បថនៅតុលាការ និងឋានៈជាភាគីក្នុងកិច្ចដំណើរការនីតិវិធី៖*

២២. ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវធ្វើសក្ខីកម្ម នៅក្នុងអំឡុងពេលជំនុំជម្រះក្តី មិនធ្វើសម្បថទេ យោងតាមវិធាន២៣(៤) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក៖ *"ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានគេសាកសួរដូចជាសាក្សីធម្មតាក្នុងរឿងក្តីតែមួយនេះបានទេ ហើយ [...] អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬ*

[11] ដូចខាងលើ កថាខណ្ឌ៨។

*ជនជាប់ចោទដែរ*”។

២៣. បែបបទនេះស្របគ្នានឹងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា៣១២ នៃក្រមនេះផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់ចម្លើយនូវឋានៈមួយខុសពីសាក្សី ដោយសារតែសក្ខីកម្មរបស់ពួកគេត្រូវធ្វើឡើង ដោយគ្មានការស្បថជាមុន។

២៤. ការលើកលែងការស្បថនេះត្រូវបានបញ្ជាក់តាមរយៈឋានៈរបស់ពួកគេជាភាគីក្នុងរឿងក្តីដែលប្រាថ្នាចង់បានការប្រកាសពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលជាមូលដ្ឋានចាំបាច់នៃសំណើសុំសំណងរបស់ពួកគេ។ ដូចគ្នានឹងមេធាវីការពារក្តីដែរ ការប្រាថ្នាចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនូវលទ្ធផលជាក់លាក់នៃការជំនុំជម្រះក្តី ធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីខុសគ្នាដាច់ស្រឡះពីស្ថានភាពរបស់សាក្សី។

២៥. សហមេធាវីការពារក្តីលោក អៀង សារី បានចាត់ទុកស្ថានភាពបែបនេះថាមានលក្ខណៈ “លម្អៀង”[12]។

២៦. ការសន្និដ្ឋានបែបនេះកើតចេញពីការភាន់ច្រឡំអំពីតួនាទីរបស់អ្នកអន្តរាគមន៍ផ្សេងៗ ក្នុងអំឡុងពេលជំនុំជម្រះក្តី។ ជាក់ស្តែង សាក្សីមិនត្រូវបានតម្រូវឱ្យមានអនាគតិទាល់តែសោះ ដែលពាក្យនេះមានន័យថាមិនលម្អៀង និងមិនមានបុរេវិនិច្ឆ័យ។ គេតម្រូវឱ្យសាក្សីមានករណីយកិច្ចស្មោះត្រង់ក្នុងការពិពណ៌នាអង្គហេតុ ហើយការតម្រូវឱ្យធ្វើស្បថគឺមានមានគោលដៅពង្រឹងករណីយកិច្ចនោះ។ ផ្ទុយទៅវិញ អនាគតិគឺជាល័ក្ខខ័ណ្ឌតម្រូវជាចាំបាច់សម្រាប់ចៅក្រម ក្នុងការរៀបចំមតិយោបល់របស់ខ្លួន និងក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធី ពោលគឺភាគីមិនត្រូវបានទាមទារឱ្យមានអនាគតិទាល់តែសោះ។

២៧. ជាក់ស្តែង ភាគីក្នុងរឿងក្តីទាំងនេះ ជាអាទិ៍ ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញតាមធម្មជាតិ និងតាមនិរុត្តិសាស្ត្រ នូវលក្ខណៈលម្អៀង ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការស្វែងរកផលប្រយោជន៍របស់ពួកគេក្នុងអំឡុងដំណើរការជម្រះក្តី។ ប៉ុន្តែ ទោះក្នុងករណីណាក៏ដោយ “ពាក្យលម្អៀង” ដែលមេធាវីការពារក្តីលោក អៀង សារី បានស្តីបន្ទោសដោយមិនសម

[12] សំណើរបស់សហមេធាវីលោក អៀង សារី ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ E57 កថាខណ្ឌ៧។

ហេតុផលទៅលើដើមបណ្តឹងរដ្ឋប្បវេណី មិនមែនជាសទិសសន័យ ឬជាផលវិបាកនៃឥរិយាបថបំផ្លាញកិច្ចពិភាក្សាដេញដោលក្នុងតុលាការ ការមិនស្មោះត្រង់ ការភូតកុហក ឬអសុទ្ធចិត្តឡើយ។ ដូចគ្នាផងដែរ វាមិនសមហេតុផលឡើយ ក្នុងការស្តីបន្ទោសមេធាវីការពារក្តីថា ខ្វះអនាគតិ ឬមានភាពលម្អៀង។

២៨. ជាចុងក្រោយ គ្មានភាគីណាមួយក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ទោះជាជនជាប់ចោទ ឬសហព្រះរាជអាជ្ញាក៏ដោយ មិនត្រូវបានតម្រូវឲ្យធ្វើសម្បថឡើយ ហើយចំណុចនេះមិនត្រូវបានជំទាស់ដោយសហមេធាវីការពារក្តីលោក អៀង សារី នៅក្នុងសំណើរបស់ខ្លួនឡើយ។ នៅក្នុងល័ក្ខខ័ណ្ឌទាំងនេះ គោលការណ៍សមភាពរវាងភាគីនៅចំពោះមុខកិច្ចដំណើរការនីតិវិធី និងសមភាពនៃមធ្យោបាយតទល់ក្តី ប្រឆាំងនឹងការតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ មុនពេលធ្វើសក្ខីកម្ម។

## សេចក្តីសន្និដ្ឋាន

២៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា សំណើរបស់សហមេធាវីការពារក្តីលោក អៀង សារី សុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ នៅពេលធ្វើសក្ខីកម្មក្នុងអំឡុងពេលជំនុំជម្រះក្តី ផ្ទុយនឹងបទបញ្ញត្តិគ្រប់គ្រងនីតិវិធីនៅចំពោះមុខ អ.វ.ត.ក និងតុលាការព្រហ្មទណ្ឌកម្ពុជា ហើយមិនទទួលស្គាល់ទាំងស្រុងនូវគោលការណ៍ទូទៅនៃប្រព័ន្ធច្បាប់រ៉ូម៉ាណូហ្សែរម៉ានិក (Civil Law) ដែលកំណត់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

៣០. អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- ជាចម្បង ប្រកាសថាអង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការក្នុងការសម្រេចលើសំណើរបស់សហមេធាវីការពារក្តីលោក អៀង សារី។
- ជាបន្ទាប់បន្សំ កត់សម្គាល់ថាសំអាងហេតុនៃសំណើនេះមិនស្របនឹងបទបញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងវិធាននៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយបដិសេធសំណើនេះចោល។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលនូវសេចក្តីគោរពអំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ១៨មីនា២០១១ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |
| | ឡោ ជុនធី<br>មេធាវីជាតិ | | |
| | Olivier Bahougne<br>មេធាវីអន្តរជាតិ | | ជ. |